# ប្រាសាទគោកចក

ប្រាសាទគោកចកមានទីតាំងនៅក្នុងភូមិគោកចក សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប មានចំងាយប្រហែល៣គ.មខាងជើងឈៀងខាងលិចក្រុងសៀមរាប។ វាត្រូវបានកត់ត្រាជាលើកដំបូងដោយលោក H. Marchal ក្នុងឆ្នាំ១៩១៩[១] និងជាប្រាសាទពុំទាន់មានការចុះបញ្ជីដោយលោក ឡាហ្សង់ហ្គិយេ និងលោក អែម៉ូនីញេ៉ទេ។ ប្រាសាទនេះសង់ឡើងអំពីឥដ្ឋ លំអដោយគ្រឿងស្ថាបត្យកម្មអំពីថ្មភក់ នៅលើខឿនថ្មបាយក្រៀមមួយជាន់ និងបន្តដោយកំពលឥដ្ឋជុំវិញ។ ប្រាសាទនេះមានប្រាង្គ២ បែរមុខទៅរកទិសខាងកើត មានច្រកចូល១ពីទិសខាងកើត និងព័ទ្ធដោយកស្សិណទឹកមួយ (រូបលេខ១)។ នៅលើស៊ុំទ្វាររបស់ប្រាង្គទាំង២នេះមានសិលាចារឹក ដែលមានកាលបរិច្ឆេទឆ្នាំខុសគ្នា ហើយលោកសឺដេសបានឱ្យលេខបញ្ជីរួមគ្នា គឺ K.៥២១។ សិលាចារិកទាំងពីរនេះមិនបាននិយាយអំពីឆ្នាំនៃការស្ថាបនាទេ តែតាមសិលាចារឹកនៅប្រាង្គខាងជើង[២] បានសរសេររំលឹកអំពីឆ្នាំដែលព្រះរាជាឈ្មោះ **ជ័យវរ្ម័ន** (**វិស្ណុលោក**) ដែលជាបុត្រារបស់**ព្រះបាទបរមេស្វរៈ** (**ជ័យវរ្ម័នទី២**) បានមកទាក់ដំរីនៅតំបន់នោះ (**វិស្ណុគ្រាម=ភូមិព្រះវិស្ណុ**) ហើយដំរីដែលព្រះអង្គបានរត់បាត់វិញ លុះវេលាយប់ពេលដែលព្រះអង្គផ្ទុំ បានយល់សុបិន្តឃើញព្រាហ្មណ៍មួយមកបន្ទូលប្រាប់ឱ្យព្រះអង្គកសាងប្រតិមា និងមានភក្តី (គោរព) ដល់គាត់ៗនឹងប្រគល់ដំរីឱ្យវិញនៅថ្ងៃស្អែកពេលព្រះអាទិត្យរះ (ឧទ័យ)។ ដំរីនោះក៏ត្រលប់មកវិញមែន ហើយព្រះអង្គបានបង្គាប់ឱ្យគេត្ការព្រៃ និងសាងប្រាសាទដោយមានថ្វាយទាសាទាសីនៅបំរើប្រាសាទនោះផងដែរ។ សិលាចារឹកនោះមានបញ្ជាក់ពីឆ្នាំដែលព្រះអង្គមកទាក់ដំរី គឺ៧៧២ស.ក គឺត្រូវនិង៨៥០គ.ស ដូចនេះប្រាសាទនេះអាចត្រូវបានគេស្ថាបនាក្នុងឆ្នាំនោះ ឬក្រោយនោះបន្តិច តែការចារសិលាចារិកនោះមិនមែនស្ថិតនៅក្នុងឆ្នាំនោះទេ គឺក្រោយមកទៀត បន្ទាប់ពីព្រះបាទជ័យវរ្ម័ទេវបានចូលទីវង្គត់ហើយ (**វិស្ណុលោក=ជ័យវរ្ម័នទី៣**)

---

[១] BEFEO, Tome XIX, 5, p.125

[២] លោកសឺដេសមានការយល់ច្រលំលើទីតាំងសិលាចារិកនេះ។ សិលាចារិកនេះស្ថិតនៅលើស៊ុំទ្វារខាងត្បូងនៃទ្វារខាងកើតរបស់ប្រាង្គខាងជើង។ រីឯលោកសឺដេសថានៅលើទ្វាររបស់ប្រាង្គខាងត្បូង។

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

ព្រោះក្នុងសិលាចារឹកបានបង្ហាញអំពីមរណៈនាមរបស់ព្រះអង្គ។ សិលាចារឹកនៅសុំទ្វារខាងកើតនៃប្រាង្គខាងត្បូងពុំមានកាលបរិច្ឆេទទេ តែនិយាយអំពីការឧទ្ទិសដល់ទេពឈ្មោះ **ស្រីវិរៈលក្ស្មី** (**កម្រតេង អញ ស្រី វិរៈលក្ស្មី អជី**) និងការសង់គោលដីធ្វីនៅវិស្ណុគ្រាមក្នុងរាជ្យព្រះបាទ**បរមនិពាន្វបទ** (សូរ្យវរ្ម័នទី១ គ.ស១០០២ដល់១០៥០)។

រចនាសម្ព័ន្ធសំណង់ប្រាសាទនេះបានបាក់បែករលុះបាត់អស់ស្ទើរទាំងស្រុងនៅផ្នែកខាងលើ។ សព្វថ្ងៃ យើងអាចឃើញត្រឹមប្រាង្គទាំងពីរ និងមានគ្រឿងលំអស្ថាបត្យកម្មធ្វើអំពីថ្មភក់ពណ៌ប្រផេះនៅផ្នែកខាងកើត។ តាមចម្លាក់នៅលើផ្តែររបស់ប្រាង្គខាងត្បូងបង្ហាញអំពីចម្លាក់គ្រុឌចាប់នាគនៅផ្នែកកណ្តាលនៃផ្ទៃផ្តែរ តែធ្វើមិនទាន់រួច។ ចំណែកផ្តែរខាងកើតរបស់ប្រាង្គខាងជើងត្រូវបានគេឆ្លាក់រួចរាល់ហើយ និងក៏មានចម្លាក់ដូចផ្តែររបស់ប្រាង្គខាងត្បូងដែរ គឺចម្លាក់គ្រុឌចាប់នាគ។ ទោះពុំមានចម្លាក់ផ្សេងទៀតដែលអាចបង្ហាញថាប្រាសាទនេះឧទ្ទិសដល់ព្រះវិស្ណុ តែតាមចម្លាក់លើផ្ទៃផ្តែរ និងសិលាចារឹកទាំងពីរ ក៏ជាភស្តុតាងបញ្ជាក់ថាប្រាសាទនេះកសាងឡើងដើម្បីឧទ្ទិសដល់ព្រះវិស្ណុ និងព្រះនាងលក្ស្មីដែរ ពោលគឺ៖ (១)យោងតាមមរណៈនាមព្រះបាទជ័យវរ្ម័នទី៣ វិស្ណុលោក (២) ប្រាសាទនេះសង់ក្នុង ភូមិឋានព្រះវិស្ណុ វិស្ណុគ្រាម (៣) ចម្លាក់គ្រុឌចាប់នាគ ដែលតំណាងឱ្យយានជំនិះព្រះវិស្ណុ (៤) ការឧទ្ទិសដល់ទេពស្នងឈ្មោះស្រីវីរលក្ស្មីចាស់ (កម្រតេង អញ ស្រីវីរលក្ស្មី អជី)។

## ១. ប្រាង្គខាងត្បូង

តាមស្ថានភាពបច្ចុប្បន្ន ផ្នែកកំពូលរបស់ប្រាង្គខាងត្បូងបានបាក់រលំអស់ទាំងស្រុង គឺនៅសល់ត្រឹមផ្នែកខាងក្រោមនៃហោជាងចុះមកក្រោមប៉ុណ្ណោះ (រូបលេខ២)។ ជាលក្ខណៈទូទៅ ប្រាង្គនេះសាងអំពីឥដ្ឋ នៅលើខឿនថ្មបាយក្រៀមមួយជាន់ មានទ្វារចូលនៅទិសខាងកើត និងទ្វារបញ្ឆោត៣ផ្សេងទៀតនៅតាមទិសនីមួយៗ។ បង់បាតខាងក្នុងមានរាងជាការ៉េ រីឯខាងក្រៅមានបន្ថែមជាក្បាច់ជ្រុងលយផតនៅតាមជ្រុងនីមួយៗផងដែរ។ ពុំមានចម្លាក់អ្វីជាសំខាន់នៅលើផ្ទៃជញ្ជាំងរបស់ប្រាង្គនេះទេ។ ទ្វារចូលសំខាន់នៅខាងកើត ធ្វើអំពីថ្មភក់ពណ៌ប្រផេះចំនួន៤ដុំតំរៀបត្រួតលើគ្នាបង្កើតបានជាសុំទ្វារ។ សុំទ្វារផ្នែកខាងក្រោមមានស្ថានភាពបែកសិករេចរិលអស់មួយភាគធំ។ ទ្វារនៅតាំទិស៣ផ្សេងទៀតជា

ទ្វារបញ្ឆោត។ ទ្វារខាងកើតលម្អដោយសសរពេជ្រ ដែលខាងត្បូងបានបាត់ នៅសល់តែសសរពេជ្រខាងជើងទ្រផ្តែរ។ សសរពេជ្រធ្វើពីថ្មភក់ពណ៌ប្រផេះ មានរាងជាធកោណ មានក្បាច់ក្បាលសសរ តួសសរ ជើងសសរ និងបាតសសរ។ ប៉ុន្តែសសរពេជ្រនេះនៅមិនទាន់បានឆ្លាក់រួចឡើយ គឺមានតែជ្រុងមួយក្នុងចំណោមជ្រុងទាំង៦របស់វាទេ ដែលត្រូវបានឆ្លាក់ចេញជាក្បាច់លំអផ្សេងៗ។ តាមរយៈជ្រុងមួយនេះ យើងអាចឃើញថា ក្បាលសសរលំអដោយក្បាច់ចិញ្ចៀន ដូចជា ក្បាច់ក្បាំងជាផ្កាចាន់ (សិកអស់ហើយ) មួយបន្ទះ និងខាងក្រោមបន្តដោយក្បាច់ត្របកផ្កាឈូកតូចបញ្ឈរមួយជួរ ក្បាច់ពងត្រីជាផ្ការំដួលក្រពុំមួយជួរ ក្បាច់សន្ទឹកបញ្ឈរមួយជួរ ក្បាច់ត្របកផ្កាឈូកធំបញ្ឈរមួយជួរ ក្បាច់ពងត្រីជាផ្ការំដួលក្រពុំមួយជួរ ក្បាច់សន្ទឹកតូចសំយ៉ុងចុះក្រោមមួយជួរ និងក្បាច់សន្ទឹកធំសំយ៉ុងចុះក្រោម។

ផ្តែរធ្វើពីថ្មភក់ពណ៌ប្រផេះ មានស្ថានភាពល្អ តែនៅមិនទាន់ធ្វើឬឆ្លាក់រួចហើយ (រូបលេខ២៣)។ ផ្នែកកណ្តាលនៃក្បាច់ដួង ជារូបគ្រុឌឈរចាប់កន្ទុយនាគ២ (ក្បាល៣) ផ្សេងៗគ្នា ដោយដៃឆ្វេង និងជើងឆ្វេងចាប់ និងកាន់នាគ១ ហើយដៃស្តាំ និងជើងស្តាំចាប់ និងកាន់នាគមួយផ្សេងទៀត។ ក្បាច់ដងផ្កូលេចចេញពីសងខាងនៃក្បាលគ្រុឌ រាងត្រង់បន្តិច រួចកាច់ធ្លាក់ចុះក្រោម ហើយកោងបែរចេញក្រៅ បង្កើតបានជាក្បាលមករខ្ជាក់ក្បាច់សន្ទឹកមានរាងជាក្បាលនាគបែរចេញក្រៅ។ ផ្នែខាងក្រោមនៃផ្តែរជាក្បាច់កំរងគូទខ្សែនៃភ្ញីទេសធ្លាក់ចុះក្រោម រួចកោងឡើងលើបែរទៅរកផ្នែកកណ្តាលនៃផ្តែរ។ ក្បាច់នេះមានចំនួន២ក្នុងម្ខាងៗ។ អវត្តមានគែមខាងក្រោម និងក្បាច់ក្បាលសសរ។ គែមខាងលើមាន តែមិនមានចម្លាក់អ្វីទេ (ធ្វើមិនទាន់រួច)។

នៅលើស៊ុំទ្វាររបស់ប្រាង្គខាងត្បូងនេះមានសិលាចារឹក១ផ្ទាំង (រូបលេខ២៤) ដែលលោកសឺដេសមានការយល់ច្រលំលើទីតាំងសិលាចារឹកទាំង២របស់ប្រាសាទគោកចក[1]។ ក្នុងអត្ថបទបញ្ជីសិលាចារឹកកម្ពុជារបស់លោកបានបង្ហាញថា សិលាចារឹករបស់ប្រាង្គខាងត្បូងមានចំនួន១៥បន្ទាត់ រីឯសិលាចារឹករបស់ប្រាង្គខាងជើងមាន ១៦បន្ទាត់។ តាមពិត

---

[1] G. Cedes, (1952:167-170)

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

សិលាចារឹករបស់ប្រាង្គខាងត្បូងមានចំនួន១៦បន្ទាត់ ចារឡើងក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី១ (បរមនិពានបទ) ចំណែកសិលាចារឹកប្រាង្គខាងជើងមាន១៥បន្ទាត់ ចារឡើងក្រោយរាជ្យព្រះបាទជ័យវរ្ម័នទី៣ (វិស្ណុលោក) តែរំលឹកដល់ឆ្នាំដែលព្រះអង្គបានមកស្ថាបនាបដិមា និងប្រហែលប្រាសាទនេះផងដែរ ដើម្បីឧទ្ទិសដល់សកព្រាហ្មណ៍។

*(១)លុះហ ត រាជ វ្រះ បាទ បរមនិវ្វានបទ មន នេហ ភូម្យ រាជទ្រាវ្យ យោក ប្រសា(២)ទ ទៅ ត កម្រតេង អញ ស្រីវីរលក្ស្មី អជិ អញ ម្វាយ តោយ មាត្របក្ស ផ្ទះ (៣) លោញ ផុន ជា តំម្រូច កម្រតេង អញ ស្រីវីរលក្ស្មី វំលិក ត កម្រតេ(៤)ង អញ ស្រីវីរលក្ស្មី លេង មាន គោល អំវិ អាយ លុហ ភូម្យ ផ្នង ប្រាង (៥) លេង កំពិ មាន ឧប្បវាទ ចំន្យរ កម្រតេង អញ ស្រីវីរលក្ស្មី បង្គំ (៦) ថ្វង និវេថន ស្វំ សភា បន្ទូល ប្រេ សភាបតិ តបូន ត ផ្ទះ វ្រះ យនបតិ (៧) ចាស វ្រះ កុត៌ុង ចាស វ្រះ មោក ចាស វ្រះ ន្នុរ ចាស វង្សាង ត បូន វ្រះ មទ(៨)សិង្គ វ្រះ ស្រោ វ្រះ បញ្ចោម រាង្គបុរ សេនាបតិ ត បូន វ្រះ តស្វរនិវាស វ្រះ (៩) ថ្វល ខ្វស ចាស វ្រះ នា ទោ វ្រះ ស្វយ នុ សវ្វាធិការិ ត ផ្ទះ វ្រះ បុកណេក ចាស ស្យ(១០)ង ត ចុះ មោក សង គោល ត ភូម្យ អាយ វិស្ណុគ្រាម នុ ស្រុក ត ចូល ត កម្រតេង អញ (១១) ស្រីវីរលក្ស្មី ផោង។ ត បូរ្វ ប្រសប ត អវ. . ទក្សិណ . . . បច្ឆិម ប្រស(១២)ប សារ ឧត្តរ ប្រសប ន្នុកន្ទាល ភូម្យផ្នង . . . . . . . . គ្រម បច្ឆិ(១៣)ម ប្រសប ផ្ទេង បន្ទេំ ឧត្តរ វីគ្រាម . . . . . . . . បូរ្វ (១៤) ភូម្យ វ្រះ រូប បច្ឆិម ប្រសប . . . . . . . . . . ត វ្យរ (១៥) ផយ បិយ តប ប្រាម តិ បូរ្វ ១០ប . . . . . . . . . . គោល ថ្មោ ១ (១៦) គោល ឈេ ១*

**២. ប្រាង្គខាងជើង**

ប្រាង្គខាងជើងមានប្លង់បាតដូចគ្នាទៅនិងប្រាង្គខាងត្បូង តែមានទំហំតូចជាងបន្តិច។ ប្រាង្គនេះមានទ្វារចូលនៅទិសខាងកើត និងទ្វារបញ្ឆោទ៣ផ្សេងទៀតនៅតាមទិសផ្សេងៗទៀត (រូបលេខ៥)។ សព្វថ្ងៃ ប្រាង្គនេះបាក់រលំនៅសល់ត្រឹមពាក់កណ្ដាលនៃសសរពេជ្រចុះមកក្រោម។ ផ្ទៃជញ្ជាំងខាងក្នុងមានបន្សល់កស្ដុតាងជាបាយអរស្តើងៗ ហើយមានលាបពណ៌ក្រហមទៀតផង។ ស៊ុំទ្វារខាងកើតធ្វើអំពីថ្មភក់ពណ៌ប្រផេះ មាន៤ជុំផ្គុំលើគ្នា។ នៅលើផ្ទៃនៃស៊ុំទ្វារផ្នែកខាងត្បូងមានសិលាចារឹកមួយផ្ទាំង (K.521)។ តាមរយៈរូបថតចាស់របស់បារាំង សិលាចារឹកនេះនៅមានស្ថានភាពល្អទាំងអស់ តែក្រោយមកវាត្រូវ

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

បានបំផ្លាញដោយគ្រាប់កាំភ្លើង គឺផ្នែកខ្លះនៃសិលាចារឹកត្រូវបានបែកខ្ទេច (រូបលេខ២៦)។ សសរពេជ្រធ្វើពីថ្មភក់ពណ៌ប្រផេះ ចំនួន២ មានលក្ខណៈដូចគ្នាទៅនិងសសរពេជ្ររបស់ប្រាង្គខាងត្បូង គឺមាន៦ជ្រុង តែមានកំពស់ទាបជាងបន្តិច និងត្រូវបានធ្លាក់រួចរាល់ទាំងស្រុង។ នៅលើសសរពេជ្រមានផ្តែរធ្វើអំពីថ្មភក់ពណ៌ប្រផេះ ត្រូវបានធ្លាក់ហើយទាំងស្រុង។ ក្បាច់ចម្លាក់នៅលើផ្តែរមានលក្ខណៈដូចគ្នាទាំងស្រុងទៅនិងផ្ទៃផ្តែររបស់ប្រាង្គខាងត្បូង (រូបលេខ២៧)។

នៅលើជញ្ជាំងខាងត្បូងរបស់ស៊ុំទ្វារខាងកើត មានសិលាចារឹកមួយផ្ទាំង ដែលលោកសឺដេសបានដាក់លេខបញ្ជី ៥២១។ សិលាចារឹកនេះសរសេរជាភាសាខ្មែរ មាន១៥បន្ទាត់ ចារឡើងក្រោយឆ្នាំ ៧៧២ស.ក រំលឹកដល់ព្រះបាទជ័យវរ្ម័នទី៣ ដែលជារាជ្យបុត្ររបស់ព្រះបាទជ័យវរ្ម័នទី២ ដែលបានឱ្យគេស្ថាបនាប្រាសាទនេះឡើងដើម្បីឧទ្ទិសដល់ព្រាហ្មណ៍មួយឈ្មោះ **សកព្រាហ្មណ៍** នៅទីឋានឈ្មោះ **វិស្ណុគ្រាម**។

*(១)៧៧២ សក គិ នុ វ្រះបាទ ស្រិជៃវរ្ម័ទេវ ស្តាច ទៅ វិស្ណុលោក ត រាជបុត្រ (២) វ្រះបាទ បរមេស្វរ វ្រះ..អិ. ប៉ែ្រ ស្វា អនិន ស្វយ រាជ ឆ្នាំ តប ប្រ(៣)ម្វាយ ចាប តំម្រ្យ ទុក..... លាង មន តំម្រ្យ រត ចូល ត ប៉ែ្រ (៤) នេហ ត ផ្មហ វិស្ណុគ្រាំម យប ផ្ទុំ ត គិ ស្វំ ប្រត្យាទេស យោល កម្រ(៥)តេង អញ វ៉ៃស្នវ ម្វាយ បន្ទូល ត វ្រះ បាទ វិស្ណុលោក ថា ទ(៦)ហ ញ្យាង វិ.... បិ ស្ថាប រូប អញ កក្តិ អញ ឱ្យ តំម្រ្យ(៧) នោហ វិញ ឱទ័យ គុហ អម្បាន តំម្រ្យ នោហ ត ប៉ែ្រ នេហ បន្ទូល (៨) ប្រេ ក្តា ត នេហ ស្ថាបនា រូប្ឋ កម្រតេង អញ សកព្រាហ្មណ ទិ(៩) ក្សា ផ្មហ វិស្ណុគ្រាំម ដូន ភូមិ ត្រិយ ផ្សង ប្រាំង អជិ អញ ក្ញុំ បញ្ចាំ (១០) ម្វាយ ផ្មហ តេង ហៀង ជា ស្វាមិយ លោញ លស វ្រះ ខ្ញៃយ តោ(១១)យ វ្រះ ទ្វាយ មោក ដូន ត វ្រះ នេហ ប្រេ បំរេ បន្ទស វ្រះ សរិរ៚*

*(១២) តេង ហៀង នុ លោញ លស បង្គំ ប្បូង និវេទន ស្វំ ភូមិ នុ យេង ក្ញុំ (១៣) បំប្យម បំរេ ត ជា ចំរ្យេង.. វ្រះ បាទ កម្រតេង អញ ករុណា ប្រ(១៤)សាទ ភូមិ សោត អាយ. . . អមោឃបុរៈ ចំនត វ្យរ ណានិវាស ចំន(១៥)ត ទូក ត្នោង៚*

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

## អត្ថបទ៖ ប្រាសាទគោកចក (សៀមរាប)

ជាសង្ខេប ប្រាសាទគោកចក ជាប្រាសាទមួយដែលស្ថាបនាអំពីឥដ្ឋ និងថ្មភក់ ឧទ្ទិសដល់ទេពវិស្ណុឈ្មោះ **សកព្រាហ្មណ៍** នៅទីឋានឈ្មោះ **វិស្ណុគ្រាម**។ តាមសិលាចារឹកនៅប្រាង្គខាងជើង ប្រាសាទនេះអាចត្រូវបានស្ថាបនាក្រោមការបញ្ជារបស់ព្រះបាទជ័យវម៌្ម ទី៣ (៨៣៦គ.សដល់៨៧៧គ.ស) ជាថ្នូរនិងការទទួលបានមកវិញនូវដំរីដែលព្រះអង្គចាប់បានហើយរត់ចូលព្រៃបាត់។ ប៉ុន្តែសិលាចារឹកដែលនិយាយអំពីរឿងនេះគឺចារនៅពេលក្រោយការចូលទីវង្គត់របស់ព្រះអង្គ រំលឹកឡើងវិញនូវសកម្មភាពដែលព្រះអង្គជាក្សត្រចូលចិត្តការទាក់ដំរី។ ក្រោយមកទៀតមានការប្រទាននូវអំណោយជាវត្ថុ និងមនុស្សដល់ទីប្រាសាទនេះ ក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី១ (១០០២គ.សដល់១០៥០គ.ស)។

ឯកសារពិគ្រោះ

BEFEO, Tome XIX, 5, p.125

G. Cedes, (1952), *Inscription du Cambodge*, Tome IV, EFEO, Paris.




រូបលេខ១៖ ប្លង់ប្រាសាទគោកចក

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា



រូបលេខ២២៖ ប្រាង្គខាងត្បូងប្រាសាទគោកចក



រូបលេខ២៣៖ ផ្តែររបស់ប្រាង្គខាងត្បូង

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា



រូបលេខ២៨៖ សិលាចារឹកលើស៊ុំទ្វាររបស់ប្រាង្គខាងត្បូង



រូបលេខ២៩៖ ប្រាង្គខាងជើងប្រាសាទគោកចក

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា



រូបលេខ២៦៖ សិលាចារឹកប្រាង្គខាងជើង



រូបលេខ២៧៖ ផ្តែរទ្វារប្រាង្គខាងជើង